# គោលជំនឿរបស់ពួកសាវ័ក

## The Apostles´ Creed

ខ្ញុំជឿលើព្រះវរបិតាដ៏មានអំណាចគ្រប់ព្រះចេស្តា

ព្រះអង្គគឺជាព្រះអាទិករបង្កើតឋានសួគ៌និងភពផែនដី។

ខ្ញុំជឿលើព្រះយេស៊ូវគ្រីស្ទគឺជាព្រះរាជបុត្រាតែមួយនៃព្រះវរបិតា ដែលជាព្រះជាម្ចាស់របស់យើង

ព្រះអង្គបានកើតជាមនុស្សដោយឫទ្ធានុភាពព្រះវិញ្ញាណបរិសុទ្ធ

ហើយបានប្រសូតចេញពីនាងក្រមុំព្រហ្មចារីម៉ារា។

ព្រះអង្គបានរងទុក្ខវេទនានៅក្រោមកណ្តាប់ដៃរបស់ប៉ុនទាសពីឡាត់

ដោយជាប់លើឈើឆ្កាង ហើយបានសុគត ហើយព្រះបរមសពបានទទួលការបញ្ចុះ។

ព្រះអង្គបានយាងចុះទៅស្ថានឃុំព្រលឹងមនុស្សស្លាប់។

នៅថ្ងៃទីបីព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ។

ព្រះអង្គបានយាងទៅកាន់ឋានសួគ៌ហើយគង់នៅខាងស្តាំព្រះវរបិតា

ព្រះអង្គនឹងយាងត្រឡប់មកវិញដើម្បីវិនិច្ឆ័យមនុស្សទាំងអស់

ទោះទាំងមនុស្សរស់និងមនុស្សស្លាប់។

ខ្ញុំជឿលើព្រះវិញ្ញាណបរិសុទ្ធ និងជឿលើពួកជំនុំដ៏បរិសុទ្ធ

ហើយការចងសម្ពន្ធជាមួយពួកអ្នកដ៏បរិសុទ្ធ

ហើយការលើកលែងទោសពីអំពើបាប

ហើយការរស់ឡើងវិញនៃរូបកាយ

និង ជីវិតអស់កល្បជានិច្ច។ អាម៉ែន។